ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ
សំណុំរឿងព្រហ្មទណ្ឌលេខ:៤២៣
ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០
សាលក្រមលេខ:៣២(ឃ)
ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១

# ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តតាកែវ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ:នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។

បានបើកសវនាការជាសាធារណៈនៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តតាកែវ នាថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ម៉ោង០៨និង៣០នាទី ដោយមានសមាសភាពដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted]ក្រមសាលាដំបូងខេត្តតាកែវ ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តតាកែវ ជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តតាកែវ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

ដើម្បីជំនុំជម្រះលើជនជាប់ចោទដែលមានដូចខាងក្រោម៖

១.ឈ្មោះ [redacted] ឆារ៉ា ហៅ ជ្រុក ភេទប្រុស អាយុ១៨ឆ្នាំ កើតឆ្នាំ២០០២ សញ្ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ កំរិតវប្បធម៌ថ្នាក់ទី៤ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ[redacted] ខេត្តតាកែវ និងទីលំនៅមុនពេលចាប់ខ្លួនភូមិ[redacted] ខេត្តតាកែវ។ ឪពុកឈ្មោះ [redacted] មោក (រស់) ម្តាយឈ្មោះ [redacted] ច្រិច (រស់) នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ និងឃុំខ្លួនថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២០ ។

២.ឈ្មោះ [redacted] ផានិត ហៅ ឆែម ភេទប្រុស អាយុ២០ឆ្នាំ កើតឆ្នាំ២០០០ សញ្ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ កំរិតវប្បធម៌ថ្នាក់ទី៤ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត និងទីលំនៅមុនពេលចាប់ខ្លួនភូមិ [redacted] ខេត្តតាកែវ។ ឪពុកឈ្មោះ [redacted] សារឿន (រស់) ម្តាយឈ្មោះ [redacted] គៀង (រស់) នៅលីវ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារខេត្តតាកែវ ចំនួន០២ឆ្នាំ ចាប់ខ្លួនថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ និងឃុំខ្លួនថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ ។

៣.ឈ្មោះ [redacted] ម៉ីនឡុង ហៅ ឡុង ភេទប្រុស អាយុ២០ឆ្នាំ កើតឆ្នាំ២០០០ សញ្ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ កំរិតវប្បធម៌ថ្នាក់ទី៩ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត និងទីលំនៅមុនពេលចាប់ខ្លួនភូមិ [redacted] ខេត្តតាកែវ។ ឪពុកឈ្មោះ [redacted] សុខា (រស់) ម្តាយឈ្មោះ [redacted] សៀប (រស់) នៅលីវ ទោសពីមុនគ្មាន ចំនួន០២ឆ្នាំ ចាប់ខ្លួនថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ និងឃុំខ្លួនថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ ។

-ជាប់ចោទពីបទ អំពើលួច ប្រព្រឹត្តនៅភូមិកំពង់ហ្លួង ឃុំអង្គរបុរី ស្រុកអង្គរបុរី ខេត្តតាកែវ កាលពីថ្ងៃទី ០៩ និងទី១០ ខែកក្កដា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

-ដោយមានលោក [redacted] ជាមេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ហៅ ជ្រូក ។

-ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីមានឈ្មោះៈ

១.ឈ្មោះ [redacted] សំអាត ភេទប្រុស អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមេកាកំពង់ ទីលំនៅភូមិកំពង់ហ្លួង ឃុំអង្គរបូរី ស្រុកអង្គរបូរី ខេត្តតាកែវ ។

២.ឈ្មោះ [redacted] ម៉ាច ភេទប្រុស អាយុ៤២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាងដែក ទីលំនៅភូមិព្រៃកផ្ទោល ស្រុកអង្គរបូរី ខេត្តតាកែវ ។

+បានឃើញដីកាសន្និដ្ឋានស្ថាពរលេខៈ៩២៩ដ.ស.ព/២០ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ ។

+បានឃើញដីកាដំណោះស្រាយលេខៈ៤៨៤១/២០ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ ។

+បានឃើញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខៈ៩១២/២០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តតាកែវ ។

## ដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង២២និង៣០នាទី ស្ថិតភូមិកំពង់ហ្លួង ឃុំអង្គរបូរី ស្រុកអង្គរបូរី ខេត្តតាកែវ មានករណី អំពើលួច មួយកើតឡើង ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ហៅ ជ្រូក ភេទប្រុស អាយុ១៧ឆ្នាំ,ឈ្មោះ [redacted] ជានិត ហៅ ផែប ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ [redacted] ប៊ុនឡុង ហៅ ឡុង ភេទប្រុស អាយុ២០ឆ្នាំ បានធ្វើសកម្មភាពលួចម៉ូតូមួយគ្រឿង [redacted] វេវ ពណ៌សគ្មានស្លាកលេខ ដែលជារបស់ជនរងគ្រោះឈ្មោះ [redacted] សំអាត ភេទប្រុស អាយុ៤៥ឆ្នាំ។ លុះដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង២៣និង៣០នាទី ឈ្មោះ [redacted] ជានិត និងឈ្មោះ [redacted] ធារ៉ា បានធ្វើសកម្មភាពលួចម៉ូតូមួយគ្រឿង ម៉ាកC១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៣ ពាក់ស្លាកលេខៈភ្នំពេញ១CQ-៩៩៧៨ ដែលជារបស់ជនរងគ្រោះឈ្មោះ [redacted] ម៉ាច ភេទប្រុស អាយុ៤២ឆ្នាំ។ បន្ទាប់ពីលួចម៉ូតូបានជនជាប់ចោទទាំង០៣នាក់ខាងលើបានយកម៉ូតូនោះ ទៅដូរយកថ្នាំញៀនពីឈ្មោះ [redacted] សុភ័ក្រ្ត ភេទប្រុស អាយុ២០ឆ្នាំ។

ក្រោយពេលកើតហេតុនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ សមត្ថកិច្ចបានឃាត់ខ្លួនជនជាប់ចោទខាងលើ រួចកសាងសំណុំរឿងបញ្ជូនមកសាលាដំបូងខេត្តតាកែវ ដើម្បីចាត់ការតាមនីតិវិធី ។

## នាពេលសវនាការ

-បានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-បានស្តាប់ចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី

-បានស្តាប់ចម្លើយរបស់សាក្សី

-បានពិនិត្យវត្ថុតាង និងភស្តុតាង

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-បានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-បានពិភាក្សាក្រុមប្រឹក្សាជំនុំជម្រះ

## តុលាការ

## ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថាៈ



Scanned with CamScanner

+តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ហៅ ជ្រូក បានបញ្ជាក់ថា ខ្លួនកើតនៅឆ្នាំ២០០៤ ហើយអាយុពិតប្រាកដ១៨ឆ្នាំ។ នៅថ្ងៃមិនចាំ និងថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ខ្លួននិងឈ្មោះ [redacted] ផានិត ពិតជាបានធ្វើសកម្មភាពលួចម៉ូតូចំនួន០២គ្រឿង មួយគ្រឿងម៉ាកវេវ និងមួយគ្រឿងទៀតម៉ាកC១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០១៣ ប្រាកដមែន។ បន្ទាប់ពីលួចម៉ូតូខាងលើបាន ពួកខ្លួនបានយកទៅលក់ឲ្យឈ្មោះ ភ័ក្រ្ត បានតំលៃ០១គ្រឿង១០០$(មួយរយដុល្លារ)។ លុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ចំពោះឈ្មោះ [redacted] ប៊ុនឡុង ពុំមានពាក់ព័ន្ធក្នុងករណីនោះទេ ពីព្រោះគាត់មិនដែលធ្លាប់ដើរលេងជាមួយពួកខ្លួនឡើយ ។

+តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ផានិត** ហៅ ឆែប បានបញ្ជាក់ថា នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ ខ្លួននិងឈ្មោះ [redacted] ធារ៉ា ពិតជាបានធ្វើសកម្មភាពលួចម៉ូតូបានចំនួន០២គ្រឿងប្រាកដមែន ដោយមួយគ្រឿងម៉ាកវេវ ពណ៌ស គ្មានស្លាកលេខ និងមួយគ្រឿងទៀតម៉ាកC១២៥ ពណ៌ខ្មៅ។ បន្ទាប់ពីលួចបានម៉ូតូខាងលើហើយ ពួកខ្លួនបានយកម៉ូតូនោះទៅលក់ឲ្យឈ្មោះ [redacted] ភ័ក្រ្ត ក្នុងមួយគ្រឿង១០០$(មួយរយដុល្លារ)។ លុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង តែមិនបានដកហូតអ្វីពីខ្លួនទេ។ ដោយឡែកឈ្មោះ [redacted] ប៊ុនឡុង ពុំមានពាក់ព័ន្ធជាមួយពួកខ្លួនឡើយ ។

+តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនឡុង** ហៅ ឡុង បានបញ្ជាក់ថា កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង២២និង៣០នាទី ឈ្មោះ [redacted] ធារ៉ា ហៅ ជ្រូក និងឈ្មោះ [redacted] ផានិត ហៅ ឆែប បានបបួលខ្លួនធ្វើសកម្មភាពលួចម៉ូតូនៅស្រុករង្គសុរិ តែខ្លួនមិនបានចូលរួមទេ។ កន្លងមកខ្លួនក៏ពុំដែលបានធ្វើសកម្មភាពលួចជាមួយអ្នកទាំងពីរម្តងណាឡើយ សូម្បីតែការទំនាក់ទំនង និងដើរលេងជាមួយគ្នាក៏ពុំមានពេលដែរ យូរៗជួបគ្នាដើរលេងម្តងម្កាល។ ចំពោះឈ្មោះ [redacted] ធារ៉ា និងឈ្មោះ [redacted] ផានិត ខ្លួនបានដឹងពីផែនការណ៍របស់ពួកគេ ទើបខ្លួនបានរាការណ៍ជូនសមត្ថកិច្ច។ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ នៅពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំនោះ គឺពាក់ព័ន្ធក្នុងករណីប្រើប្រាស់សារធាតុញៀនទេ ហើយសមត្ថកិច្ចបានដកហូត ថ្នាំញៀនចំនួន០១កញ្ចប់តូច ទូរស័ព្ទដៃ០២គ្រឿង ម៉ាកOPPO(អូប៉ូ) និងឈូតាវ៉ិនចុចពិល ពីខ្លួនមែន ។

+តាមអំណានចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សំអាត** បានបញ្ជាក់ថា នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ ខ្លួនបានទុកម៉ូតូមួយគ្រឿងម៉ាកវេវ (យួន) ពណ៌ស គ្មានស្លាកលេខ នៅមុខតូបផ្សារដែករបស់ខ្លួន ដោយពុំបានដកកូនសោរចេញទេ លុះព្រឹកឡើងថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ម៉ូតូខាងលើបានបាត់ ហើយខ្លួនបានបើកកាមេរ៉ាសុវត្ថិភាពឃើញមានចោរចូលលួចម៉ូតូនៅវេលាម៉ោង២២និង៣០នាទី បន្ទាប់មកខ្លួនបានដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ច។ លុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ សមត្ថកិច្ចបានឃាត់ខ្លួនក្រុមជនល្មើសដែលលួចម៉ូតូរបស់ខ្លួនខាងលើនេះបាន កសាងសំណុំរឿងមកតុលាការរហូតមកដល់សព្វថ្ងៃ។

ក្នុងរឿងនេះខ្លួនមិនទាមទារសំណងពីក្រុមជនល្មើសទេ តែសុំឲ្យតុលាការផ្តន្ទាទោសតាមច្បាប់ ។

+តាមអំណានចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ម៉ាច** បានបញ្ជាក់ថា នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង២៣និង៣០នាទី ខ្លួនត្រឡប់មកពីផ្សារដែកវិញ បានដាក់ម៉ូតូទុកលើចិញ្ចើមថ្នល់មុខផ្ទះរបស់ខ្លួន រួចដើរចូលទៅក្នុងផ្ទះមួយសន្ទុះធំ ហើយរៀបនឹងដេកខ្លួនបានដើរចេញពីផ្ទះមកមើលម៉ូតូ ស្រាប់តែចោរលួចម៉ូតូយកទៅបាត់ ហើយខ្លួនបានស្រែកឆោឡោ និងទូរស័ព្ទទៅប្តឹងសមត្ថកិច្ចឲ្យជួយរកម៉ូតូរបស់ខ្លួន។ ម៉ូតូដែលបាត់នោះ ម៉ាកC១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០១៣ ពាក់ស្លាកលេខ:១CQ-៩៩៧៨ ។

ក្នុងរឿងនេះ ខ្លួនសុំទាមទារសំណងអន្តរាយចំនួន៣.០០០$(បីពាន់ដុល្លារ) និងសុំឲ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

+តាមរំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] **សានីត** បានបញ្ជាក់ថា នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ពេលរសៀល ឈ្មោះ [redacted] ធារ៉ា ហៅ ជ្រូក និងឈ្មោះ [redacted] ជានិត ហៅ ឆែប បាននាំខ្លួនអង្គុយនិយាយគ្នាលេង នៅក្នុងវត្តកំពង់ហ្លួង ពេលនោះខ្លួនបានលឺពួកគេនិយាយថា ប៉ុន្មានថ្ងៃមុនពួកគេបានលួចម៉ូតូគេយកទៅលក់ ពេលខ្លួនបាននិយាយថា ពួកឯងកុំនិយាយលេងសើចច្រើនពេក ប្រយ័ត្នគេចាប់ដាក់គុក ក្រោយមកពួកគេក៏ឈប់និយាយ ហើយខ្លួនបានដើរមកផ្ទះ ។

+តំណាងអយ្យការបានសន្និដ្ឋានថា ក្រោយពីបានស្តាប់ការសួរដេញដោលខាងលើ ឃើញថា ពិតជាមានអង្គហេតុនៃ **អំពើលួច** កើតឡើងកាលពីថ្ងៃទី០៩ និង១០ ខែកក្កដា ឆ្នាំ២០២០ នៅភូមិកំពង់ហ្លួង ឃុំអង្គរបូរី ស្រុកអង្គរបូរី ខេត្តតាកែវ ពិតប្រាកដមែន ដែលអំពើនេះបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **ធារ៉ា** ហៅ ជ្រូ ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ [redacted] ជានិត ហៅ ឆែប ភេទប្រុស អាយុ២០ឆ្នាំ។ ហេតុនេះតំណាងអយ្យការប្តឹងសុំរក្សាការចោទប្រកាន់ និងសុំឲ្យផ្តន្ទាទោសលើជនជាប់ចោទខាងលើពីបទ អំពើលួច តាមមាត្រា ៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] ប៊ុនឡុង ភេទប្រុស អាយុ២០ឆ្នាំ ស្នើសុំឲ្យតុលាការពិនិត្យពិចារណាសម្រេចតាមច្បាប់ ។

+លោក [redacted] ជាមេធាវីការពារជនជាប់ចោទឈ្មោះ [redacted] **ធារ៉ា** បានធ្វើសេចក្តីសន្និដ្ឋានថា នៅចំពោះមុខតុលាការនេះកូនក្តីរបស់ខ្លួនបានឆ្លើយសារភាពដោយស្មោះត្រង់ ឥតលាក់លៀមអ្វីឡើយ ហើយកូនក្តីរបស់ខ្លួនជាអនីតិជន ស្ថិតនៅក្នុងវ័យសិក្សារៀនសូត្រ មានការយល់ដឹងទាប មានជីវភាពក្រលំបាក និងមានការសោកស្តាយចំពោះទង្វើរបស់ខ្លួនដែលបានប្រព្រឹត្តកន្លងមក ។

ដូច្នេះ ខ្លួនជាមេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ស្នើសុំឲ្យតុលាការពិនិត្យជួយសម្រាលទោសដល់កូនក្តីខ្លួន ដោយអនុគ្រោះ ។

## <u>**យល់ឃើញថា**</u>

+តាមចម្លើយរបស់ជនជាប់ចោទ ចម្លើយជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយសាក្សី និងសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ និងមេធាវីការពារជនជាប់ចោទ បញ្ជាក់ថា ពិតជាមានអង្គហេតុនៃ **អំពើលួច** កើតឡើងនៅភូមិកំពង់ហ្លួង ឃុំអង្គរបូរី ស្រុកអង្គរបូរី ខេត្តតាកែវ កាលពីថ្ងៃទី០៩ និងទី១០ ខែកក្កដា ឆ្នាំ២០២០ ដែលប្រព្រឹត្តឡើងដោយឈ្មោះ [redacted] ធារ៉ា ហៅ ជ្រូក ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ [redacted] ជានិត ហៅ ឆែប ភេទប្រុស អាយុ២០ឆ្នាំ ពិតប្រាកដមែន។

+តាមចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយរបស់សាក្សី និងសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ និងមេធាវី ព្រមទាំងវត្ថុតាង និងភស្តុតាងនានាដែលសមត្ថកិច្ចប្រមូលបាន មានលក្ខណៈស៊ីចង្វាក់គ្នាយ៉ាងខ្លាំង ដែលអាចកំណត់បានថា ជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ហៅ ជ្រូក និងឈ្មោះ [redacted] ជានិត ហៅ ឆែប ពិតជាប្រព្រឹត្ត **អំពើលួច** បានធ្វើសកម្មភាពលួចម៉ូតូ០២ គ្រឿង របស់ជនរងគ្រោះឈ្មោះ [redacted] សំអាត ភេទប្រុស អាយុ៣៥ឆ្នាំ និងឈ្មោះ [redacted] ម៉ាច ភេទប្រុស អាយុ៤២ឆ្នាំ ប្រព្រឹត្តនៅភូមិកំពង់ហ្លួង ឃុំអង្គរបូរី ស្រុកអង្គរបូរី ខេត្តតាកែវ កាលពីថ្ងៃទី០៩ និងទី១០ ខែកក្កដា ឆ្នាំ២០២០ ពិតប្រាកដមែន។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

+តាមការអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនឡុង បានបញ្ជាក់ថា ខ្លួនមិនបានចូលរួមប្រព្រឹត្តដូចការចោទប្រកាន់ទេ ការអះអាងនេះមានលក្ខណៈស៊ីចង្វាក់គ្នាទៅនិងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ធារ៉ា និងឈ្មោះ [redacted] ជានិត ដែលបានបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] ប៊ុនឡុង មិនបានចូលរួមប្រព្រឹត្តជាមួយពួកខ្លួនឡើយ។ ដូច្នេះតុលាការគប្បីឲ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនឡុង រួចផុតពីបទចោទខាងលើ ។

+ជនជាប់ចោទដែលជានីតិជន និងជាអនីតិជន មានស្មារតីគ្រប់គ្រាន់ប្រព្រឹត្តបទល្មើសដោយដឹងខុសត្រូវ តែគប្បីតុលាការអនុវត្តតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ លើជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ជាអនីតិជន



Scanned with CamScanner

ដោយជនជាប់ចោទស្ថិតក្នុងភាពក្រីក្រផងនោះ គប្បីតុលាការផ្តល់ស្ថានអនុគ្រោះស្របតាមមាត្រា៩៨ នៃក្រមព្រហ្មទណ្ឌ ។

+អំពើប្រព្រឹត្តរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម របៀបរៀបរយសាធារណៈ ប៉ះពាល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ដែលត្រូវបានច្បាប់ការពារ ។

+ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សំអាត មិនប្តឹងទាមទារសំណងពីជនជាប់ចោទទេ ដូច្នេះ តុលាការពុំគប្បីពិចារណាលើបញ្ហានេះឡើយ។ ដោយឡែកដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ាច បាន ប្តឹងទាមទារសំណងអន្តរាយ និងជម្ងឺចិត្តពីជនជាប់ចោទខាងលើចំនួន៣.០០០$(បីពាន់ដុល្លារ) តុលាការគប្បី លើកយកបញ្ហានេះមកពិចារណា ដោយគិតជាប្រាក់រៀល ទៅតាមសភាពជាក់ស្តែង ។

+វត្ថុតាងចាប់យករួបមាន៖

១.ផ្លាកលេខម៉ូតូចំនួន០៤,ទូរស័ព្ទដៃមួយគ្រឿង ម៉ាកSony(សូនី),ដំពាមចំនួន០២,កាំបិតចំនួន០១ កន្ត្រៃ០១ កញ្ចក់ម៉ូតូ០២គូរ បូមម៉ូតូ០១ ក្បាលបាញ់ហ្គាសចំនួន០១ ក្បាលពិល០២ តុលាការគប្បីរឹបអូស និង បំផ្លាញចោល ។

២.ម៉ូតូមួយគ្រឿង ម៉ាកKTM DUCK ពណ៌ទឹកប្រាក់លាយខ្មៅ ពាក់ស្លាកលេខៈ១FD-៩១១៧ ជាបច្ចោបាយប្រព្រឹត្តបទល្មើស តុលាការគប្បីសម្រេចរឹបអូសជាសម្បត្តិរដ្ឋ ។

## ហេតុដូច្នេះសាលាដំបូងខេត្តតាកែវ

## វិនិច្ឆ័យសេចក្តី

១.ឲ្យរួចផុតពីការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ម៉ិនឡុង ភេទប្រុស អាយុ២០ឆ្នាំ (សាវតាជាតិខាងលើ) ពីបទ អំពើលួច ប្រព្រឹត្តនៅភូមិកំពង់ហ្លួង ឃុំអង្គរបូរី ស្រុកអង្គរបូរី ខេត្តតាកែវ កាលពីថ្ងៃ ទី០៩ និងទី១០ ខែកក្កដា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

២.ផ្តន្ទាទោសជនជាប់ចោទដែលមានឈ្មោះ

ក.ឈ្មោះ [redacted] ធារ៉ា ហៅ ជ្រូក ភេទប្រុស កើតឆ្នាំ២០០២ (មានសាវតាជាតិខាងលើ)

ខ.ឈ្មោះ [redacted] ផានិត ហៅ ឆែប ភេទប្រុស អាយុ២០ឆ្នាំ (មានសាវតាជាតិខាងលើ)

-ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន១៨(ដប់ប្រាំបី)ខែ គិតពីថ្ងៃឃុំខ្លួន ។

ពីបទ អំពើលួច ប្រព្រឹត្តនៅភូមិកំពង់ហ្លួង ឃុំអង្គរបូរី ស្រុកអង្គរបូរី ខេត្តតាកែវ កាលពីថ្ងៃទី០៩ និង ទី១០ ខែកក្កដា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា៩៧ និងផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៣.បង្គាប់ឲ្យដោះលែងឈ្មោះ [redacted] ម៉ិនឡុង ភេទប្រុស អាយុ២០ឆ្នាំ (សាវតាជាតិខាងលើ) ជា បន្ទាប់ប្រសិនបើជនជាប់ចោទរូបនេះមិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងៗទៀតឡើយ ។

៤.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ហៅ ជ្រូក និងឈ្មោះ [redacted] ផានិត ហៅ ឆែប រួមគ្នាសង សំណងអន្តរាយ និងជម្ងឺចិត្តឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ាច ចំនួន៦.០០០.០០០(ប្រាំមួយ លាន) រៀល ។

-ការទាមទារលើសពីនេះត្រូវលើកចោល ។

៥.វត្ថុតាងចាប់យករួបមាន៖

ក.ផ្លាកលេខម៉ូតូចំនួន០៤,ទូរស័ព្ទដៃមួយគ្រឿង ម៉ាកSony(សូនី),ដំពាម០២ កាំបិត០១ដើម កន្ត្រៃ ០១ កញ្ចក់ម៉ូតូ០២គូរ បូមម៉ូតូ០១ ក្បាលបាញ់ហ្គាស០១ ក្បាលពិល០២ ត្រូវ - រឹបអូស និងបំផ្លាញចោល ។



Scanned with CamScanner

ខ.ម៉ូតូមួយគ្រឿង ម៉ាកKTM DUCK ពណ៌ទឹកប្រាក់លាយខ្មៅ ពាក់ស្លាកលេខ:១FD-៩១១៧ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

-សាលក្រមនេះជំនុំជម្រះសាធារណៈនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤

តាកែវ,ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

| | |
| --- | --- |
| បានឃើញ<br>ប្រធានក្រុមប្រឹក្សាជំនុំជម្រះ<br>[redacted] | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម<br>ថ្ងៃព្រហស្បតិ៍ ៧កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤<br>តាកែវ,ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១<br>ក្រឡាបញ្ជី<br>[redacted] |